# សាធារណរដ្ឋប្រជាមានិតកម្ពុជា

## ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា

អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទីប្រាំបី ស្តីអំពីការបង្ការបទឧក្រិដ្ឋ និងការគ្រប់គ្រងជនល្មើស នាទីក្រុង ហាវ៉ាណា នៃប្រទេសគុយបា នៅថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩០ ។

ដោយហេតុថា នៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ប្រជាពលរដ្ឋគ្រប់ជាតិសាសន៍ នៅលើពិភពលោក បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួន ថានឹងបង្កើតនូវលក្ខខណ្ឌដែលអាចរក្សាបាននូវភាពយុត្តិធម៌ និងបានប្រកាសតាមគោលបំណងមួយក្នុងចំណោមគោលបំណងទាំងឡាយរបស់ ខ្លួនអំពីការធ្វើឲ្យបានសម្រេចនូវកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការលើកស្ទួយនិងលើកទឹកចិត្ត ដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដោយឥតមានការបែងចែកពូជសាសន៍ ភេទ ភាសា ឬសាសនាឡើយ ។

ដោយហេតុថា សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស បានតម្កល់ទុកនូវគោលការណ៍ សមភាពចំពោះមុខច្បាប់ ការសន្មត់ជាមុនថាគ្មានទោសពៃរ៍ និងសិទ្ធិទទួលការជំនុំជម្រះក្តីដ៏ត្រឹមត្រូវ និងជាសាធារណៈមួយពីតុលាការឯករាជ្យ និងមិនលំអៀង ។

ដោយហេតុថា ជាញឹកញាប់នៅមានចន្លោះមួយរវាងទស្សនៈយល់ឃើញវែងឆ្ងាយដែលកំណត់គោលការណ៍ទាំងនោះជាមូលដ្ឋាន និងស្ថានការណ៍ពិត ។

ដោយហេតុថា ការរៀបចំនិងការគ្រប់គ្រងយុត្តិធម៌ នៅតាមបណ្តាប្រទេសទាំងឡាយត្រូវតែធ្វើតាមគោលការណ៍ទាំងនោះ ហើយត្រូវខិតខំប្រឹងប្រែងធ្វើការបកស្រាយគោលការណ៍ទាំងនោះឲ្យក្លាយជាការពិតយ៉ាងពេញលេញ ។

ដោយហេតុថា ព្រះរាជអាជ្ញាមានតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងយុត្តិធម៌ និងវិធានច្បាប់នានា ដែលទាក់ទងទៅនឹងការអនុវត្តតាមការទទួលខុសត្រូវដ៏សំខាន់របស់ខ្លួនគួរតែលើកស្ទួយការគោរព និងការប្រតិបត្តិតាមរបស់ខ្លួនចំពោះគោលការណ៍ទាំងឡាយដែលបានពោលខាងលើ ដូច្នេះនាំឲ្យមានការចូលរួមចំណែកដើម្បីភាពយុត្តិធម៌ខាងព្រហ្មទណ្ឌដ៏សមរម្យ សមភាព និងដើម្បីប្រជាពលរដ្ឋ ឲ្យមានប្រសិទ្ធិភាពប្រឆាំងនឹងឧក្រិដ្ឋកម្ម ។

ដោយហេតុថា ជាការចាំបាច់ត្រូវធានាថា ព្រះរាជអាជ្ញាមានលក្ខណៈសម្បត្តិជំនាញដែលតម្រូវក្នុងការបំពេញមុខងាររបស់ខ្លួនឲ្យបានសម្រេច តាមរយៈរូបមន្តនៃការជ្រើសរើសដ៏ល្អប្រសើរ និងការហ្វឹកហ្វឺនផ្នែកច្បាប់និងជំនាញហើយនិងការមរយៈការផ្តល់នូវគ្រប់មធ្យោបាយចាំបាច់ ដើម្បីគោលការណ៍ណែនាំដូចមានចែងខាងក្រោមនេះដែលត្រូវបានបរៀបចំឡើងយ៉ាងជាក់លាក់ដើម្បីជួយដល់រដ្ឋជាសមាជិកក្នុងការងាររបស់ខ្លួន ដើម្បីធានានិងលើកស្ទួយប្រសិទ្ធិភាព ភាពមិនលំអៀង និងភាពត្រឹមត្រូវរបស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ គប្បីត្រូវបានគោពតាមនិងយកទៅពិចារណាដោយរដ្ឋាភិបាលក្នុងក្របខ័ណ្ឌនៃនីតិកម្មជាតិ និងការអនុវត្តន៍របស់ខ្លួនហើយគួរតែផ្សព្វផ្សាយដល់ព្រះរាជអាជ្ញា ព្រមទាំងអ្នកឯទៀតៗ ដូចជាចៅក្រម មេធាវី សមាជិក សាខាអង្គនីតិប្រតិបត្តិ អង្គនីតិបញ្ញត្តិ និងសាធារណៈជនជាទូទៅ ។ គោលការណ៍ណែនាំបច្ចុប្បន្ន ត្រូវបានរៀបចំឡើងជាសំខាន់គឺសំដៅចំពោះព្រះរាជអាជ្ញាសាធារណៈ ក៏ប៉ុន្តែគោលការណ៍ទាំងនេះអនុវត្តបានដោយស្មើភាពគ្នា ក្នុងលក្ខណៈសមស្របចំពោះព្រះរាជអាជ្ញាទាំងឡាយដែលត្រូវបានតែងតាំងឡើងនៅលើមូលដ្ឋានពិសេសផងដែរ។

### <u>លក្ខណៈសម្បត្តិ ការជ្រើសរើស និងការហ្វឹកហ្វឺន</u>

៦-ជនទាំងឡាយដែលត្រូវបានជ្រើសរើសធ្វើជាព្រះរាជអាជ្ញា ត្រូវតែជាឯកត្តជនដែលមានសេចក្តីសុចរិតនិងមានសមត្ថភាពទាំងមានការហ្វឹកហ្វឺន និងលក្ខណៈសម្បត្តិសមរម្យផង ។

**២.រដ្ឋទាំងឡាយត្រូវធានថា ៖**

(ក)លក្ខណៈជ្រើសរើសព្រះរាជអាជ្ញាត្រូវមានការការពារមិនគួរមានការតែងតាំងទាំងឡាយណារីដែលឈរលើភាពលំអៀង ឬបុរេនិច្ឆ័យ ដោយបំបាត់ចោលនូវរាល់ការរើសអើងណាមួយប្រឆាំងនឹងបុគ្គលនៅលើមូលដ្ឋានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិយោបាយ ឬមតិផ្សេងទៀត សញ្ជាតិដើម ឋានៈសង្គម ឬជាតិពន្ធ ទ្រព្យសម្បត្តិ ដើមកំណើត ឋានៈសេដ្ឋកិច្ច ឬឋានៈដទៃទៀត លើកលែងតែការតម្រូវឲ្យបក្ខជនសម្រាប់ការិយាល័យអយ្យការនោះ ត្រូវតែមានសញ្ជាតិ នៃប្រទេសសាមីប៉ុណ្ណោះ ដែលគេមិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

(ខ)ព្រះរាជអាជ្ញាត្រូវមានការអប់រំ និងការហ្វឹកហ្វឺនត្រឹមត្រូវហើយត្រូវឱ្យយល់ដឹងអំពីឧត្តមគតិ និងករណីយកិច្ចប្រកបដោយសីលធម៌នៃតួនាទីរបស់ខ្លួនដឹងអំពីការការពាររដ្ឋធម្មនុញ្ញ និងច្បាប់ចំពោះសិទ្ធិរបស់ជនជាប់សង្ស័យនិងជនរងគ្រោះហើយក៏ត្រូវយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលទទួលស្គាល់ដោយច្បាប់ជាតិនិងច្បាប់អន្តរជាតិផង ។

**ឋានៈ និងលក្ខខណ្ឌ នៃសេវាកម្ម**

៣-ក្នុងនាមជាភ្នាកងារដ៏សំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ព្រះរាជអាជ្ញាត្រូវរក្សាខ្ជាប់គ្រប់ពេលវេលានូវកិត្តិយស និងសេចក្តីថ្លៃថ្នូនៃវិជាជីវៈរបស់ខ្លួន ។

៤-រដ្ឋត្រូវធានាថាព្រះរាជអាជ្ញា មានលទ្ធភាពអាចបំពេញមុខងារតាមវិជ្ជាជីវៈរបស់ខ្លួនដោយគ្មានការបំភិតបំភ័យការបញ្ឆក់ការយាយីរំខាន ការជ្រៀតជ្រែកមិនសមស្រប ឬដាក់ឲ្យទទួលខុសត្រូវខាងរដ្ឋប្បវេណីព្រហ្មទណ្ឌ ឬវិស័យដទៃទៀតដោយមិនសមហេតុផល ។

៥-ព្រះរាជអាជ្ញា និងក្រុមគ្រួសាររបស់គេ ត្រូវតែមានកិច្ចការពារខាងផ្លូវកាយពីសំណាក់អាជ្ញាធរនៅពេលណាដែលសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេទទួលនូវការគំរាមកំហែង ដោយសារតែការបំពេញមុខងារជាព្រះរាជអាជ្ញានោះ

៦-ការកំណត់លក្ខ័ណ្ឌសេវាកម្មដ៏សមហេតុផលរបស់ព្រះរាជអាជ្ញាប្រាក់ទូទាត់គ្រប់គ្រាន់ សម្រាប់ការងារដែលបានធ្វើ និងនៅទីណាដែលអាចអនុវត្តបានរយៈពេលកាន់មុខតំណែង ប្រាក់សោធន និងអាយុចូលនិវត្តន៍ត្រូវតែមានចែងក្នុងច្បាប់ ឬវិធាន ឬបទបញ្ជាទាំងឡាយដែលបានចេញផ្សាយ ។

៧-ការតម្លើងឋានៈព្រះរាជអាជ្ញា នៅទីណាក៏ដោយដែលមានប្រព័ន្ធបែបនេះត្រូវផ្អែកលើកក្តាសត្យានុម័តនានាជាពិសេសគឺលក្ខណៈសម្បត្តិខាងវិជ្ជាជីវៈ សមត្ថភាព សេចក្តីសុចរិត និងបទពិសោធន៍ ហើយត្រូវសម្រេចឲ្យបានស្របតាមនីតិវិធីត្រឹមត្រូវ និងមិនលំអៀង ។

**សេរីភាពក្នុងការបញ្ចេញមតិ និងបង្កើតសមាគម**

៨-ព្រះរាជអាជ្ញា ក៏ដូចជាប្រជាពលរដ្ឋដទៃទៀតដែរ គឺមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិជំនឿការបង្កើតសមាគម និងការប្រជុំ ជាពិសេសព្រះរាជអាជ្ញាមានសិទ្ធិចូលរួមចំណែកក្នុងការពិភាក្សាជាសាធារណៈនូវរាល់បញ្ហាដែលទាក់ទងនឹងច្បាប់ការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ ការជំរុញ និងការពារសិទ្ធិមនុស្ស ព្រមទាំងការចូលរួម ឬបង្កើតអង្គការប្រចាំតំបន់ អង្គការជាតិ ឬអន្តរជាតិ និងចូលរួមការប្រជុំរបស់គេ ដោយគ្មានការទទួលរងនូវការបាត់បង់ផលប្រយោជន៍ខាងវិជ្ជាជីវៈដោយសារតែមូលហេតុនៃសកម្មភាពស្របច្បាប់ ឬដោយសារសមាជិកភាពរបស់គេនៅក្នុងអង្គកាស្របច្បាប់ណាមួយនោះឡើយ ។ ក្នុងការប្រើប្រាស់នូវសិទ្ធិទាំងអស់នេះព្រះរាជអាជ្ញាជានិច្ចជាកាលត្រូវប្រតិបត្តិខ្លួនឱ្យស្របតាមច្បាប់និងបទដ្ឋានព្រមទាំងក្រមសីលធម៌ទាំងឡាយនៃវិជ្ជាជីវៈរបស់ខ្លួន ដែលត្រូវបានគេទទួលស្គាល់ ។

៩-ព្រះរាជអាជ្ញា មានសិទ្ធិសេរីភាពក្នុងការចូលរួមនិងបង្កើតសមាគមវិជ្ជាជីវៈ ឬអង្គការដទៃទៀតដើម្បីតំណាងឲ្យផលប្រយោជន៍របស់ខ្លួន ដើម្បីលើកស្ទួយការហ្វឹកហ្វឺនវិជ្ជាជីវៈ ហើយនិងដើម្បីការពារឋានៈរបស់ខ្លួន ។

១៥-ព្រះរាជអាជ្ញា ត្រូវផ្តល់ការយកចិត្តទុកដាក់លើការធ្វើបណ្តឹងអាជ្ញាចំពោះមន្ត្រីសាធារណៈ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសពីអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ បទឧក្រិដ្ឋដទៃៗទៀតដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយនិងការស៊ើបអង្កេតអំពីបទល្មើសទាំងនេះនៅទីណាដែលមានការអនុញ្ញាតិដោយច្បាប់ ឬស្របទៅនឹងការអនុវត្តន៍តាមតំបន់ ។

១៦-នៅពេលណាដែលព្រះរាជអាជ្ញាទទួលបាននូវភស្តុតាងប្រឆាំងចំពោះជនជាប់សង្ស័យ ដែលគេដឹងឬមានជំនឿលើមូលដ្ឋានសមហេតុផលថា ភស្តុតាងទាំងនោះបានមកដោយប្រើប្រាស់វិធីមិនស្របច្បាប់ ដែលអាចចាត់ទុកបានថាជាការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សរបស់ជនជាប់សង្ស័យ ជាពិសេសទាក់ទងទៅនឹងការធ្វើទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវអមនុស្សធម៌ និងបន្ថោកបន្ទាប ឬការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតនោះព្រះរាជអាជ្ញាត្រូវបដិសេធ មិនប្រើភស្តុតាងបែបនោះប្រឆាំងនឹងជនណាម្នាក់ឡើយ ក្រៅពីអ្នកដែលបានប្រើវិធីបែបនោះខ្លួនឯង ឬត្រូវជម្រាប់ដល់តុលាការតាមនោះ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ទាំងអស់ដើម្បីធានាថាអ្នកដែលទទួលខុសត្រូវចំពោះការប្រើវិធីបែបនោះ ត្រូវបាននាំខ្លួនមកកាន់តុលាការ ។

**មុខការឆន្ទានុសិទ្ធ**

១៧-នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានប្រគល់ឲ្យនូវមុខការឆន្ទានុសិទ្ធិ ច្បាប់ វិធាន ឬបទបញ្ញាទាំងឡាយដែលបានចេញផ្សព្វផ្សាយ ត្រូវមានចែងអំពីគោលការណ៍ណែនាំ ដើម្បីលើកស្ទួយភាពយុត្តិធម៌ត្រឹមត្រូវនិងមិនប្រែប្រួលនៃវិធីធ្វើសេចក្តីសម្រេចនានាក្នុងដំណើរការធ្វើបណ្តឹងអាជ្ញា ដោយរួមទាំងការចាប់អនុវត្តន៍ ឬការលប់ចោលបណ្តឹងអាជ្ញានោះផង ។

**ជម្រើសផ្សេងៗ ក្នុងការធ្វើបណ្តឹងអាជ្ញា**

១៨-ស្របតាមច្បាប់ជាតិ ព្រះរាជអាជ្ញាត្រូវធ្វើការពិចារណាសមស្រប ក្នុងការលប់ចោលបណ្តឹងអាជ្ញាបញ្ឈប់ការរឿងក្តីដោយមានភ្ជាប់លក្ខខណ្ឌ ឬដោយឥតលក្ខខណ្ឌ ឬដោយការបង្វែររឿងព្រហ្មទណ្ឌចេញពីប្រព័ន្ធយុត្តិធម៌ជាផ្លូវការ ដោយគោរពយ៉ាងពេញលេញដល់សិទ្ធិរបស់ជនជាប់សង្ស័យនិងជនរងគ្រោះ ។ តាមគោលបំណងនេះរដ្ឋទាំងឡាយត្រូវរិះរកលទ្ធភាពឲ្យបានពេញលេញ ក្នុងការអនុម័តយកតាមគម្រោងការណ៍បង្វែរដែលមិនត្រឹមតែជួយសម្រាលបន្ទុកដ៏ច្រើនលើសលប់ របស់តុលាការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយជៀសវាងបាននូវភាពអាប់យសពីការឃុំខ្លួនមុនការជំនុំជម្រះក្តីពីដីកាចោទប្រកាន់ និងពីការកាត់ឲ្យជាប់ទោស ព្រមទាំងពីផលមិនល្អដែលអាចកើតមានពីការដាក់ទោសជាប់ពន្ធនាគារទៀតផង ។

១៩-នៅបណ្តាប្រទេសទាំងឡាយដែលព្រះរាជអាជ្ញាត្រូវបានគេផ្តល់ឲ្យនូវមុខការឆន្ទានុសិទ្ធ ដូចជាការសម្រេចថាតើត្រូវបណ្តឹងអាជ្ញាចំពោះយុវជនប្រព្រឹត្តបទល្មើសឬអត់នោះគេត្រូវតែផ្តោតការពិចារណាពិសេសៗទាំងឡាយទៅលើប្រភេទនិងទម្ងន់នៃបទល្មើស ទៅលើកិច្ចការពារសង្គម ទៅលើបុគ្គលិកលក្ខណៈនិងសាវតាររបស់យុវជននោះសិនក្នុងការធ្វើសេចក្តីសម្រេចនោះ ព្រះរាជអាជ្ញា ជាពិសេសត្រូវពិចារណាអំពីជំរើសផ្សេងៗដែលអាចមាន ដើម្បីជំនួសឲ្យការធ្វើបណ្តឹងអាជ្ញ ក្រោមច្បាប់ និងនីតិវិធីទាំងឡាយដែលពាក់ព័ន្ធស្តីពីយុត្តិធម៌សម្រាប់យុវជន ។ ព្រះរាជអាជ្ញាត្រូវព្យាយាមខិតខំឲ្យអស់ពីលទ្ធភាពរបស់ខ្លួន ក្នុងការចាត់វិធានការធ្វើបណ្តឹងអាជ្ញាចំពោះអនីតិជនតែនៅពេលណាដែលចាំបាច់ជាអប្បបរិមាប៉ុណ្ណោះ ។

**ទំនាក់ទំនងជាមួយក្រសួង ឬស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាល**

២០-ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពក្នុងការធ្វើបណ្តឹងអាជ្ញា ព្រះរាជអាជ្ញាត្រូវខិតខំឲ្យអស់ពីសមត្ថភាពក្នុងកិច្ចសហការជាមួយនគរបាល តុលាការ មេធាវី អ្នកការពារក្តីសាធារណៈ ហើយនិងជាមួយក្រសួង ឬស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាល ។

## <u>ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យ</u>

២១-បទល្មើសនឹងវិន័យរបស់ព្រះរាជអាជ្ញា ត្រូវផ្អែកទៅលើច្បាប់ ឬបទបញ្ញាស្របច្បាប់ បណ្តឹងតវ៉ាប្រឆាំងនឹងព្រះរាជអាជ្ញាដែលចោទថា ព្រះរាជអាជ្ញានោះបានប្រព្រឹត្តិយ៉ាងប្រត្យ័ក្សក្នុងលក្ខណៈមួយប្រាសចាកពីបទដ្ឋានវិជ្ជាជីវៈ ត្រូវតែដោះស្រាយឲ្យបានឆាប់រហ័ស និងត្រឹមត្រូវក្រោមនីតិវិធីសមស្រប ព្រះរាជអាជ្ញាមានសិទ្ធិទទួលសវនាការដ៏ត្រឹមត្រូវមួយ ។ សេចក្តីសម្រេច ត្រូវស្ថិតនៅក្រោមការពិនិត្យមើលឡើងវិញដែលប្រកបដោយឯករាជ្យភាព ។

២២-ដំណើរការដាក់ទណ្ឌកម្មផ្នែកវិន័យលើព្រះរាជអាជ្ញា ត្រូវធានានូវការវាយតម្លៃ និងការសម្រេចដែលមានសត្យានុម័ត ។ ការដាក់ទណ្ឌកម្ម នឹងត្រូវកំណត់សម្រេចដោយស្របតាមច្បាប់ ស្របតាមបទវិន័យវិជ្ជាជីវៈនិងស្របតាមបទដ្ឋាន និងក្រមសីលធម៌ឯទៀតដែលបានបង្កើតឡើង ហើយនិងស្របទៅតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះផង ។

## <u>ការប្រតិបត្តិតាមគោលការណ៍ណែនាំ</u>

២៣-ព្រះរាជអាជ្ញាត្រូវគោរពតាមគោលការណ៍ណែនាំបច្ចុប្បន្ននេះ គេក៏ត្រូវបង្ការ ព្រមទាំងប្រឆាំងឲ្យបានសកម្មទល់នឹងការរំលោភណាមួយដែលកើតមាន ឲ្យអស់ពីលទ្ធភាពដែលខ្លួនអាចធ្វើទៅបានផងដែរ ។

២៤-ព្រះរាជអាជ្ញាទាំងឡាយណាដែលជឿដោយមានហេតុផលគួរជឿថា មានការរំលោភណាមួយទៅលើគោលការណ៍ណនាំបច្ចុប្បន្នបានកើតឡើង ឬជិតនឹងកើតឡើងនោះត្រូវរាយការណ៍អំពីបញ្ហានោះដល់អាជ្ញាធរថ្នាក់លើរបស់ខ្លួន ហើយនៅទីណាដែលចាំបាច់ត្រូវរាយការណ៍ដល់អាជ្ញាធរ ឬអង្គការសមស្របនានាដែលត្រូវបានគេប្រគល់អំណាចឲ្យដើម្បីដោះស្រាយ ឬដើម្បីពិនិត្យមើលឡើងវិញ។